ទស្សនៈ អ្នកនិពន្ធ

វ៉ុល៣, លេខ១៤, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

# ពេលវេលាសម្រាប់កម្ពុជាគឺ ឥឡូវនេះ

បណ្ឌិត អ៊ុន យាង *

ជំងឺកូវីដ-១៩ បានធ្វើឱ្យពិភពលោកទាំងមូលធ្លាក់ក្នុងភាពជុនដាប ប៉ះពាល់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់សកល បង្កឱ្យមានវិបត្តិសេដ្ឋកិច្ចសកល ពង្រីកគម្លាតសង្គម និងនយោបាយ ព្រមទាំងបង្កឱ្យមានសក្តានុពលអាចរុញច្រានឱ្យពិភពលោកធ្លាក់ចូលទៅក្នុងសង្គ្រាមត្រជាក់ថ្មីមួយផងដែរ។ កម្ពុជា ដែលដំបូងឡើយអាចការពារខ្លួន ពីជំងឺរាតត្បាតសាកលនេះបាន តែបន្ទាប់មកបានប្រឈមនឹងការកើនឡើងភ្លាមៗនៃករណីឆ្លង និងស្លាប់នៅចន្លោះខែមីនា ដល់ខែសីហា ឆ្នាំ២០២១។ ការណ៍នេះបានបង្ខំឱ្យរាជរដ្ឋាភិបាលអនុវត្តបម្រាមគោចរតឹងរឹង ជាហេតុបង្កឱ្យមានការភ័យព្រួយពីសាធារណជន និងការលើកឡើងអំពីការចៀសមិនផុតពីគ្រោះមហន្តរាយ។

ក្រុមប្រឆាំងនឹងរាជរដ្ឋាភិបាល និងអ្នកវិភាគនយោបាយជាច្រើនបានចាត់ទុកគោលនយោបាយមួយចំនួន របស់រាជរដ្ឋាភិបាល រាប់ចាប់តាំងពីការធ្វើលទ្ធកម្មវ៉ាក់សាំងកូវីដ១៩ ដល់កាតព្វកិច្ចចាក់វ៉ាក់សាំង និងការធ្វើចត្តាឡីស័កតឹងរឹង ថាជាការរំលោភសិទ្ធិមនុស្ស។ ពួកគេបានអះអាងផងដែរថា ការចាក់វ៉ាក់សាំងកូវីដ១៩ ផលិតដោយចិន គឺជាការយកជីវិតប្រជាជនកម្ពុជាទៅធ្វើពិសោធន៍លើប្រសិទ្ធភាពវ៉ាក់សាំង ហើយការបញ្ជាទិញវ៉ាក់សាំងពីចិន គឺជាឱកាសសម្រាប់មន្ត្រីក្នុងជួររាជរដ្ឋាភិបាល ទទួលបានផលចំណេញ។ យ៉ាងណាមិញ បន្ទាប់ពីឃើញភាពជោគជ័យពីចំណាត់ការទាំងនោះ អ្នកវិភាគនយោបាយ និងក្រុមប្រឆាំងទាំងនោះ បែរជាចាត់ទុកភាពជោគជ័យនោះថាជា សំណាងដោយចៃដន្យទៅវិញ។ ជាការពិត ទស្សនៈអវិជ្ជមានទាំងនេះ បានមើលរំលង ការកៀរគរថវិកាជាតិ ការរួបរួមសាមគ្គីជាធ្លុងមួយ ការរៀបចំផែនការ និងការអនុវត្តគោលនយោបាយជាប្រព័ន្ធរបស់រាជរដ្ឋាភិបាលដែលជាប្រភពនៃភាពជោគជ័យ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះ។ ភាពជោគជ័យរបស់កម្ពុជាដែលយើងមើលឃើញជាក់ស្តែងនេះ បានធ្វើឱ្យលោក David Hutt ដែលជាអ្នកកាសែតនិងត្រូវបានគេស្គាល់ថាជាអ្នករិះគន់រាជរដ្ឋាភិបាលកម្ពុជាផងនោះ ទទួលស្គាល់ពីប្រសិទ្ធភាពនៃការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាទៅនឹងជំងឺរាតត្បាតសកលនេះ។[1]

ភាពជោគជ័យរបស់កម្ពុជា ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩នេះ គឺបង្ហាញអំពីឆន្ទៈនយោបាយរបស់អ្នកដឹកនាំក្នុងការកៀរគរធនធានមនុស្ស និងធនធានមូលធននៅក្នុងគ្រាមានវិបត្តិ។ ភាពជោគជ័យក្នុងការប្រឆាំងនឹងជំងឺកូវីដ១៩ របស់កម្ពុជា ក៏បានច្រានចោល ការអះអាងរបស់អ្នករិះគន់មួយចំនួនដែលថា កម្ពុជាមានទំនាក់ទំនងមិនសមាមាត្រនឹង

[1] David Hutt, "China Isn't the Only Reason for Cambodia's Vaccination Success," *The Diplomat*, 4 November, 2021.

* **បណ្ឌិត អ៊ុន យាង** គឺជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ចិន។ ថ្វីត្បិតតែ វ៉ាក់សាំងភាគច្រើនជាការចំណាយថវិកាដើម្បីទិញពីចិន ដោយសារទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងកម្ពុជា-ចិន ទើបអនុញ្ញាតឱ្យកម្ពុជាទទួលបានវ៉ាក់សាំងទាន់ពេលវេលា និងក្នុងបរិមាណច្រើន។

តើអ្វីជាជំហានបន្ទាប់សម្រាប់កម្ពុជា? បទពិសោធន៍ពីប្រទេសតតិយលោកបង្ហាញថា បើទោះបីជាប្រទេសទាំងនោះ មានសមត្ថភាពកៀងគរធនធាននានា ដើម្បីដោះស្រាយវិបត្តិដែលកើតឡើងជាបន្តបន្ទាប់ក៏ដោយ ប្រទេសទាំងនោះហាក់មិនសូវមានភាពជោគជ័យ ក្នុងការរក្សាការកៀរគរមូលធនទាំងនោះសម្រាប់បម្រើឱ្យការអភិវឌ្ឍប្រកបដោយចីរភាពទេ។ ជាលទ្ធ-ផល ប្រទេសទាំងនោះតែងតែត្រូវ ធ្លាក់ចូលក្នុងអន្ទាក់នៃភាពក្រីក្រ និងថែមទាំងអាចជាធ្លាក់ចូលក្នុងអន្ទាក់ជម្លោះ ថែមទៀតផង។ ចំណោទបញ្ហាសម្រាប់ប្រទេសតតិយលោកទាំងនោះរួមមាន បរិការណ៍អន្តរជាតិដែលមិនអំណោយផល កង្វះធន្ទះនយោបាយក្នុងចំណោមថ្នាក់ដឹកនាំកំពូល និងភាពទន់ខ្សោយនៃស្ថាប័នរដ្ឋាភិបាល។ ក្នុងករណីនេះ ស្ថាប័នដែលបម្រើផលប្រយោជន៍ជាតិទាំងនេះនៅតែជាកោះឧត្តមភាពដែលត្រូវបានឡោមព័ទ្ធដោយសមុទ្រដែលគ្មានប្រសិទ្ធភាព។

កម្ពុជា គឺស្ថិតនៅចំណុចប្រសព្វដ៏សមស្របមួយ ដែលអាចអនុញ្ញាតឱ្យកម្ពុជាអាចចៀសផុត ពីជោគវាសនាមិនល្អដូចប្រទេសតតិយលោកទាំងនោះ ដោយសារបរិការណ៍អន្តរជាតិមានលក្ខណៈអំណោយផលសម្រាប់កម្ពុជា។ កម្ពុជា ស្ថិតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលមានកំណើនសេដ្ឋកិច្ចឆាប់រហ័ស ជំរុញឡើងដោយមហាអំណាចសេដ្ឋកិច្ចដែលកំពុងលេចធ្លោដូចជា ចិន និងប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់ស្រាប់ដូចជា ជប៉ុន និងកូរ៉េខាងត្បូង។ ទោះបីមានការរិះគន់ លើទំនាក់ទំនងគ្រប់ជ្រុងជ្រោយរបស់ចិនជាមួយកម្ពុជា ដោយសារចិនមានគំរូមួយខុសពីគំរូរបស់បស្ចិមប្រទេស យ៉ាងណាក៏ដោយ ក៏ចិនគឺជាលេកមួយដែលអាចទុកចិត្តបាន ដែលអាចជួយជំរុញកម្ពុជាឆ្ពោះទៅគោលដៅរបស់ខ្លួន ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។ តាម រយៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ការប្រកាសជាសាធារណៈ និងសកម្មភាពច្បាស់លាស់ ដូចជាកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈបង្កើនចំណូលរដ្ឋ និងការសម្រេចគោលនយោបាយផ្អែកលើទឡ្ហីករណ៍ ថ្នាក់ដឹកនាំកម្ពុជាបានអនុវត្តធន្ទះនយោបាយ ដើម្បីដឹកនាំប្រទេសកម្ពុជាទៅកាន់គោលដៅដែលបានកំណត់។ ទោះបីជាយ៉ាងនេះក្តី បញ្ហាប្រឈមសម្រាប់កម្ពុជា នៅតែមាន។

នៅក្នុងឆ្នាំ២០១៨ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅវិទ្យាស្ថានជាតិអប់រំ ថា «*...ការដាក់ចេញគោលនយោបាយមានសារៈសំខាន់ណាស់ តែទោះយ៉ាងណាក្តី ការអនុវត្តគោលនយោបាយទាំងនោះ ប្រកបដោយជោគជ័យទាមទារឱ្យមានមន្ត្រីដែលមានភាពស្មោះត្រង់ និងសមត្ថភាពគ្រប់គ្រាន់*»។ កំណើនប្រាក់ចំណូលរបស់រដ្ឋាភិបាល និងយុទ្ធនាការក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ដោយជោគជ័យបង្ហាញថាឧត្តមភាពនៃស្ថាប័នរដ្ឋាភិបាលមួយចំនួន ពិតជាមាននៅក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងនេះក្តី បើមើលក្នុងបរិបទនៃស្ថាប័នរដ្ឋាភិបាលកម្ពុជាទាំងមូល កោះនៃឧត្តមភាពនេះមិនមែនមានតែមួយនោះទេ ប៉ុន្តែកំពុងកើតឡើងនៅច្រើនកន្លែងទៀត។ ប៉ុន្តែយើងគួរកត់សម្គាល់ គឺកោះដែលមានឧត្តមភាពមួយចំនួនស្ថិតនៅដាច់ពីគ្នានៅឡើយ។ កំណើនសេដ្ឋកិច្ចប្រកប ដោយនិរន្តរភាព ទាមទារឱ្យរដ្ឋាភិបាលពង្រីកបន្ថែមនូវស្ថាប័នរដ្ឋ ដែលមានឧត្តមភាពបែបនេះបន្ថែមទៀត និងភ្ជាប់

កោះនៃឧត្តមភាពទាំងនេះឱ្យទៅជាដែនដីក្នុងសមុទ្រប្រកបដោយប្រសិទ្ធភាព ដើម្បីអាចបំពេញនូវអ្វីដែលនាយករដ្ឋមន្ត្រីប្រាថ្នាចង់បាន នោះគឺវត្តមានមន្ត្រីរដ្ឋាភិបាលដែលមានភាពស្មោះត្រង់ និងសមត្ថភាព។

វត្តមានរបស់មន្ត្រីរដ្ឋាភិបាល ដែលមានភាពស្មោះត្រង់ និងសមត្ថភាពនេះ គឺជាមូលដ្ឋានគ្រឹះនៃធម្មានុរូបភាពយូរអង្វែងសម្រាប់គណបក្សកាន់អំណាចផងដែរ។ គេអាចលើកឡើងពីអំណះអំណាងដែលគួរឱ្យជឿជាក់បានមួយថា ប្រជាធិបតេយ្យបែបបស្ចិមប្រទេស មិនសមស្របសម្រាប់ប្រទេសទាំងអស់នោះទេ ដោយសារតែភាពខុសគ្នានៃប្រវត្តិសាស្ត្រ វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍ។ ប៉ុន្តែ គេក៏មិនអាចមើលរំលងការពិតដែរថា ប្រជាជននៃគ្រប់ប្រទេសទាំងអស់ប្រគល់ធម្មានុរូបភាពមួយផ្នែកធំដល់រដ្ឋាភិបាលរបស់គេ ផ្អែកទៅលើសមត្ថភាពក្នុងការបំពេញតួនាទី និងកាតព្វកិច្ចរបស់រដ្ឋាភិបាលនោះ។ ការសិក្សាជាច្រើន បានបង្ហាញថា ស្រដៀងគ្នាទៅនឹងប្រជាជនផ្សេងទៀតនៅក្នុងតំបន់ដែរ នៅពេលប្រជាជនកម្ពុជា គិតអំពីលទ្ធិប្រជាធិបតេយ្យ ពួកគាត់គិតពីគុណតម្លៃនៃលទ្ធិប្រជាធិបតេយ្យក្នុងការនាំសង្គមឈានទៅសម្រេចគោលដៅអភិវឌ្ឍសង្គម ជាជាងមើលទៅលើគុណតម្លៃមូលដ្ឋានឈរលើគោលការណ៍សិទ្ធិមនុស្ស និងពហុបក្សក្នុងបរិបទបស្ចិមប្រទេស។ មានន័យថា ប្រជាជនកម្ពុជាវិនិច្ឆ័យរដ្ឋាភិបាលរបស់ខ្លួនតាមរយៈសមត្ថភាព និងប្រសិទ្ធភាពរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់ប្រយោជន៍សារធារណៈ ការទប់ស្កាត់អំពើពុករលួយ និងបន្តរក្សាសមភាពសេដ្ឋកិច្ច-សង្គម។[2]

នៅក្នុងការវិភាគចុងក្រោយ ប្រវត្តិសាស្ត្របានបង្ហាញថា វិបត្តិទាំងឡាយ មិនមែនតែងតែធ្វើឱ្យប្រទេសលិចលង់រហូតនោះទេ។ ថ្នាក់ដឹកនាំដែលមានគោលដៅច្បាស់លាស់ ជាមួយនឹងគោលដៅអភិវឌ្ឍន៍ជាក់លាក់ ការភ្ញាក់រឭកនៅក្នុងសង្គមជារួម និងការយល់អំពីភាពបន្ទាន់នៃបញ្ហា មិនត្រឹមតែជួយប្រទេសឱ្យរួចផុតពីវិបត្តិនានានោះទេ ប៉ុន្តែថែមទាំងអាចប្រែក្លាយប្រទេសនោះ ឱ្យកាន់តែមានភាពរឹងមាំផ្នែកសេដ្ឋកិច្ច និងកាន់តែមានឯកភាពសង្គមទៀតផង។ ជំងឺរាតត្បាតសកលកូវីដ១៩ អាចបង្ហាញពីកាលានុវត្តភាព សម្រាប់ការផ្លាស់ប្តូរបែបនេះ។ ហើយអ្វីដែលជាតម្រូវការសម្រាប់ការផ្លាស់ប្តូរនេះ គឺការយល់អំពីភាពបន្ទាន់រួមគ្នា ដើម្បីទាញយកកាលានុវត្តភាពនេះ ហើយពេលវេលាសម្រាប់កម្ពុជាគឺឥឡូវនេះ!

Cambodia Development Center
Cambodia Development Center (@cd.centerkh)
Cambodia Development Center
Cambodia Development Center (t.me/cdcenterkh)
Building E, University of Puthisastra, #55, Street 180-184, Sangkat Boeung Raing, Khan Daun Penh
info@cd-center.org | (+855) 10 950 456 www.cd-center.org
មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

[2] Alex Chang, Yun-han Chu, and Bridget Welsh, "Southeast Asia: Sources of Regime Support," *Journal of Democracy* 24, no. 2 (2013): 150-164.